00756552

E145

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 25 / 11 / 2011
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សេចក្តីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

អនុស្សរណៈនេះបញ្ជាក់ថា ឯកសារ E141 ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ គឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើខាងលើ ដែលបានលើកបញ្ហានានាពាក់ព័ន្ធនឹងការរៀបចំសវនាការនាពេលបច្ចុប្បន្ន។ ហេតុដូច្នេះ ចម្លើយតបរបស់មេធាវីការពារក្តីជនជាប់ចោទ អៀង សារី ទៅនឹងសំណើមួយក្នុងចំណោមសំណើទាំងនេះ (ឯកសារ E136/1) ពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបង្កើតប្រព័ន្ធមួយមានប្រសិទ្ធភាពសម្រាប់ទទួលយកភស្តុតាងនៅពេលសវនាការ នឹងត្រូវអង្គជំនុំជម្រះលើកយកមកពិនិត្យពិចារណាក្នុងបរិបទនៃការរៀបចំសវនាការនាពេលបច្ចុប្បន្ន។

00756553

E145

អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងពុំអនុញ្ញាតឱ្យភាគីដាក់ចម្លើយតប និងសារណាតបទៅនឹងសំណើនេះឡើយ។ ប៉ុន្តែភាគីអាចលើកបញ្ហាទាំងនេះ និងបញ្ហាពាក់ព័ន្ធនានាទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងក្នុងបរិបទនៃកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការដើម្បីចង្អុលបង្ហាញ និងរកដំណោះស្រាយជាក់ស្តែង។

អង្គជំនុំជម្រះសូមបញ្ជាក់ថាវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុងដែលជាមូលដ្ឋាននៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិរៀបចំសវនាការ ដោយភាគីពុំមានសិទ្ធិប្តឹងសារទុក្ខឡើយ។ កាលពីថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E124/7)។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក៏បានយោងទៅលើសេចក្តីជូនដំណឹងរបស់សហមេធាវីនាំមុខអំពីសំណើសុំឱ្យអង្គជំនុំជម្រពិចារណាឡើងវិញនូវដីការបស់ខ្លួន។ ក្នុងសេចក្តីជូនដំណឹងខាងលើ សហមេធាវីបានគូសបញ្ជាក់ថាខ្លួននឹងដាក់សារណាបន្ថែម "ឆាប់ៗបន្ទាប់ពីមានការឯកភាពគ្នាក្នុងចំណោមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី" (ឯកសារ E124/4)។ ទោះបីជាមានការជូនដំណឹងរបស់សហមេធាវីនាំមុខក្តី ក៏នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បំភ្លឺថាអង្គជំនុំជម្រះត្រូវសម្រេចលើសំណើនេះឱ្យបានឆាប់រហ័សដើម្បីខ្លួនមានលទ្ធភាពធ្វើសវនាការលើអង្គសេចក្តីក្នុងសំណុំរឿងលេខ០០២ នៅឆ្នាំ ២០១១ (ឯកសារ E124/7 កថាខណ្ឌ ៦)។ ដូច្នេះ អង្គជំនុំជម្រះនឹងពុំពិចារណាឡើងវិញលើសេចក្តីសម្រេចទៅលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី E124/8 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ និង E124/10 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឡើយ ដោយហេតុថាសំណើទាំងនេះលើកបញ្ហាច្រំដែលដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចរួចម្តងហើយ។ អង្គជំនុំជម្រះសាលាដំបូងនឹងពុំឆ្លើយតបទៅនឹងសំណើទាំងឡាយ ដែលស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ទោះបីក្នុងប្រភេទជាសំណើសុំ ជា"ការបញ្ជាក់បំភ្លឺ" ជាចម្លើយតប ឬផ្សេងពីនេះក៏ដោយ ហើយការធ្វើបែបនេះ អាចត្រូវបានចាត់ទុកដោយអង្គជំនុំជម្រះថាជាការព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធី។

ទោះយ៉ាងណា អនុស្សរណៈ E141 បានឆ្លើយតបទៅនឹងបញ្ហាជាក់ស្តែងមួយចំនួនរបស់ភាគីពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងលើសំណុំរឿង០០២/០១ (រួមទាំងបញ្ហាជាច្រើនដែលសំណើទាំងប៉ុន្មានខាងលើបានលើកឡើង និងសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់បំភ្លឺ (E124/9))។ អង្គជំនុំជម្រះក៏ធ្លាប់បានបញ្ជាក់ម្តងហើយម្តងទៀតថាខ្លួននឹងចេញគោលការណ៍ណែនាំ និងសេចក្តីណែនាំបន្ថែមតាមការចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំសវនាការនាពេលបច្ចុប្បន្ន។

នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (E124) អង្គជំនុំជម្រះបានបញ្ជាក់ថា "ផ្អែកលើបទដ្ឋានគតិយុត្តជាធរមាន ដើមបណ្តឹងរដ្ឋប្បវេណីមិនចូលរួមជាលក្ខណៈបុគ្គលដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្មជាក់លាក់ដែលខ្លួនបានទទួលរងឡើយ" ហើយ "ការកម្រិតវិសាលភាពនៃអង្គហេតុដែលគ្រោងនឹងយកមកជំនុំជម្រះនៅក្នុងដំណាក់កាលដំបូងនេះ ពុំមានផលប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជំនុំជម្រះនេះឡើយ" (កថាខណ្ឌ ៨)។ មូលដ្ឋាននៃការសង្កេតនេះគឺថាសក្ខីកម្ម *ទាំងអស់* នៅសវនាការ (ទោះជាសក្ខីកម្មរបស់សាក្សីក្តី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីក្តី ) នឹងកំហិតត្រឹមសក្ខីកម្មពាក់ព័ន្ធនឹងការសម្រេចលើអង្គហេតុក្នុងសំណុំរឿង០០២/០១។ ដើមបណ្តឹងរដ្ឋប្បវេណីដែលពុំមានលទ្ធភាពផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុក្នុងសំណុំរឿង ០០២/០១ នេះ ប៉ុន្តែមានបទពិសោធន៍ពាក់ព័ន្ធនឹងកម្មវត្ថុនៃសវនាការនាពេលខាងមុខ អាចនឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មអំឡុងសវនាការទាំងនេះ។

នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះក៏បានគូសបញ្ជាក់ថា "ការទាមទារសំណង...ដែលធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏គួរគិតពិចារណាលើវិធាន ២៣ *ស្ទួនបួន* (១)(ក) នៃវិធានផ្ទៃក្នុងផងដែរ (ឯកសារ E124, កថាខណ្ឌ ៨)។ ចំណុចនេះបញ្ជាក់ថាសំណងក្នុងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក ត្រូវផ្តល់ប្រយោជន៍ទៅដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងអំពីព្យសនកម្មដោយសារការប្រព្រឹត្តិបទល្មើសដែលត្រូវបានចោទប្រកាន់មកលើជន-ជាប់ចោទ។ ហេតុដូច្នេះ ពាក់ព័ន្ធនឹងសំណងដែលបានទាមទារដោយអនុលោមតាមវិធាន ២៣ *ស្ទួនបួន* (៣)(ក) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចត្រឹមតែពិចារណាលើព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងដោយសារការប្រព្រឹត្តិ និងការចោទប្រកាន់ដែលជាមូលដ្ឋាននៃសំណុំរឿង ០០២/០១

00756555

E145

ប៉ុណ្ណោះ។ ដូចខាងលើ និងក្នុងករណីព្យសនកម្មណាមួយដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង មានជាប់ពាក់ព័ន្ធនឹងកម្មវត្ថុនៃសវនាការនៅពេលខាងមុខ ចំណុចនេះនឹងជាប់ពាក់ព័ន្ធនឹងសវនាការទាំងនេះ។ ពាក់ព័ន្ធនឹងទម្រង់ថ្មីនៃសំណងដូចមានចែងក្នុង វិធាន ២៣*ស្ទួនបួន* (៣)(ខ) (ដែលសោហ៊ុយនៃសំណងពុំមែនជាបន្ទុករបស់ទណ្ឌិត) ដីកាសម្រេចបំបែក កិច្ចដំណើរការនីតិវិធីពុំហាមឃាត់ឡើយក្នុងការបង្កើតគម្រោងណាមួយដែលផ្តល់សុពលភាពដល់សំណងដែលសហមេធាវីនាំមុខបានទាមទារ។ ផែនការណាមួយពាក់ព័ន្ធនឹងទម្រង់ថ្មីនៃសំណងនេះ (ជាពិសេសគឺផែនការដើម្បីធានាឱ្យមានការផ្គត់ផ្គង់ថវិកាពីខាងក្រៅ) អាចត្រូវបានអនុវត្តឱ្យស៊ីសង្វាក់ទៅនឹងការជំនុំជម្រះលើសំណុំ រឿង០០២ ទាំងមូល។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះសូមជំរុញសហមេធាវីនាំមុខឱ្យយកចិត្តទុកដាក់លើសំណង ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងសំណងដែលអាចអនុវត្តបានក្នុងអំឡុងពេល ឬ ឆាប់ៗក្រោយពេលអង្គជំនុំជម្រះចេញសាលក្រមលើសំណុំរឿងនោះ។

អង្គជំនុំជម្រះសូមរំឭកថាកាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១ និងថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានធ្វើសវនាការចំនួន ២ ដាច់ដោយឡែកពីគ្នា ដោយអនុលោមតាមវិធាន៨០*ស្ទួន*(៤) នៃវិធានផ្ទៃក្នុង ដោយបានស្នើឱ្យសហមេធាវីនាំមុខបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលខ្លួនមានបំណងទាមទារនៅក្នុងការទាមទារសំណងផ្លូវចិត្តជាសមូហភាពជាស្ថាពរ ដោយអនុលោមតាមវិធាន ២៣*ស្ទួនបួន*(៣)(ខ) នៃវិធានផ្ទៃក្នុង។ ត្រង់ប្រការនេះ អង្គជំនុំជម្រះទទួលស្គាល់ផលប៉ះពាល់នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ គោលបំណងនៃសវនាការទាំងនេះគឺដើម្បីទុកលទ្ធភាពឱ្យអង្គជំនុំជម្រះធ្វើការត្រួតពិនិត្យ និងណែនាំជាក់ស្តែងដើម្បីធានាបានថា សំណងដែលបានទាមទារពិតជាស្របតាមក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក និងធានាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានរបស់ម្ចាស់ជំនួយ និងធនធានផ្សេងៗ ក៏ដូចជាជួយបង្កើនលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសំណងប្រកបដោយអត្ថន័យ។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងនៅពេលក្រោយ។ តាមការចាំបាច់នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះនឹងបង្ហាញ៖

ក) ថាតើសំណងណាមួយដែលសហមេធាវីនាំមុខកំពុងមានបំណងទាមទារ ស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១

ខ) ថាតើសំណងណាមួយដែលសហមេធាវីនាំមុខបានបង្ហាញ ពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ (ដែលអង្គជំនុំជម្រះនឹងពុំលើកយកមកពិនិត្យពិចារណានៅក្នុងសវនាការនេះ) ប៉ុន្តែអាចពាក់ព័ន្ធនឹងសវនាការនាពេលខាងមុខ និង

គ) ថាតើផែនការណាមួយដែលសហមេធាវីនាំមុខបានចង្អុលបង្ហាញ អាចពុំស្ថិតនៅក្នុងវិសាលភាពនៃក្របខណ្ឌគតិយុត្ត អ.វ.ត.ក។

ជាចុងក្រោយ អង្គជំនុំជម្រះបានឃើញលិខិតចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំការបញ្ជាក់បំភ្លឺអំពីវិសាលភាពនៃការសួរសំណួរបន្ទាប់ពីមានអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានចាត់តាំងភារកិច្ចក្នុងការសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូបដែលត្រូវកោះហៅចូលសវនាការដំណាក់កាលដំបូងនេះទៅឱ្យសហមេធាវីនាំមុខ (ឯកសារ E131/10)។

អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់បំភ្លឺរួចហើយថាសវនាការដំណាក់កាលដំបូងនេះផ្តោតទៅលើផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានលើកឡើងនៅទំព័រ ២ នៃអនុស្សរណៈ E141 ពាក់ព័ន្ធទៅនឹងប្រវត្តិសាវតារ។ ទោះដូចម្តេច ដើម្បីបញ្ចៀសការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាថ្មីដោយពុំចាំបាច់ ភាគីអាចសួរសំណួរពួកគាត់លើចំណុចផ្សេងៗដែលពួកគាត់បានដឹងពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០១។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះនឹងពុំអនុញ្ញាតឱ្យមានការសួរសំណួរលើចំណុចអង្គហេតុនានាដែលពុំស្ថិតក្នុងវិសាលភាពនៃសវនាការនេះឡើយ។

ក្នុងករណីពិសេស ភាគីអាចស្នើសុំការអនុញ្ញាតដោយផ្ទាល់មាត់ទៅអង្គជំនុំជម្រះដើម្បីសួរសំណួរទៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២រួមទាំងបញ្ហាដែលអាចជាកម្មវត្ថុនៃសវនាការនាពេលខាងមុខ។ តែទោះបីជាយ៉ាងនេះក្តី សំណើរបស់ភាគីនឹងពុំងាយទទួលបានការឯកភាពពីអង្គជំនុំជម្រះឡើយ។